ក្រសួងព័ត៌មាន
MINISTRY OF INFORMATION
លេខ ១១៤ ព.ម.ប្រក

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ២០១០

# សេចក្តីជូនដំណឹង
## ស្តីពី
## ការគ្រប់គ្រងការផ្សព្វផ្សាយអាហ្វីស ប៉ាណូ ប័ណ្ណប្រកាស ស្លាកសញ្ញា តាមទីសាធារណៈ ដែលមានលក្ខណៈឃោសនាមហាជន និងការផ្សព្វផ្សាយដំណឹងពាណិជ្ជកម្ម

ក្រសួងព័ត៌មាន សូមជូនដំណឹងដល់ លោក លោកស្រី ដែលកំពុង ឬមានបំណងធ្វើអាជីវកម្មលើការផ្សព្វផ្សាយអាហ្វីស ប៉ាណូ ប័ណ្ណប្រកាស ស្លាកសញ្ញា តាមទីសាធារណៈ ដែលមានលក្ខណៈ ឃោសនាមហាជន និងការផ្សព្វផ្សាយដំណឹងពាណិជ្ជកម្ម នៅព្រះរាជាណាចក្រកម្ពុជាទាំងអស់ឱ្យបានជ្រាបថា: ក្រោយពីក្រសួងព័ត៌មាន ដាក់ឱ្យអនុវត្តប្រកាសលេខ ០៨៣ ពម.ប្រក ចុះថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០១០ ស្តីពីការគ្រប់គ្រងការផ្សព្វផ្សាយអាហ្វីស ប៉ាណូ ប័ណ្ណប្រកាស ស្លាកសញ្ញា តាមទីសាធារណៈ ដែលមានលក្ខណៈឃោសនាមហាជន និងការផ្សព្វផ្សាយ ដំណឹងពាណិជ្ជកម្មមក មានលោក លោកស្រី និងក្រុមហ៊ុនមួយចំនួនបានចុះបញ្ជី និងមកស្នើសុំអាជ្ញាប័ណ្ណធ្វើការផ្សព្វផ្សាយអំពីផលិតផលរបស់ខ្លួនជាបន្តបន្ទាប់។ ទន្ទឹមនឹងនេះក៏នៅមាន លោក លោកស្រី និងក្រុមហ៊ុនខ្លះពុំទាន់បានអនុវត្តតាមខ្លឹមសារនៃប្រកាស របស់ក្រសួងព័ត៌មាន ខាងលើនេះនៅឡើយដែរ ។

អាស្រ័យហេតុនេះ ក្រសួងព័ត៌មាន សូមណែនាំ លោក លោកស្រី និងក្រុមហ៊ុនដែលបាននឹងកំពុង ឬមានបំណងធ្វើអាជីវកម្មលើការផ្សព្វផ្សាយអាហ្វីស ប៉ាណូ ប័ណ្ណប្រកាស ស្លាកសញ្ញា តាមទីសាធារណៈ ដែលមានលក្ខណៈឃោសនាមហាជន និងការផ្សព្វផ្សាយដំណឹងពាណិជ្ជកម្ម នៅព្រះរាជាណាចក្រកម្ពុជាទាំងអស់ថា ចាប់ពីថ្ងៃជូនដំណឹងនេះតទៅ សូមប្រញាប់មកចុះបញ្ជី និងស្នើសុំអាជ្ញាប័ណ្ណផ្សព្វផ្សាយ នៅការិយាល័យគ្រប់គ្រងអាហ្វីស ប៉ាណូ នៃនាយកដ្ឋានគ្រប់គ្រងខាងពុម្ព អគ្គនាយកដ្ឋានព័ត៌មាន និងសោតទស្សន៍ នៃក្រសួងព័ត៌មាន នៅរៀងរាល់ម៉ោងធ្វើការ ចាប់ពីថ្ងៃជូនដំណឹងនេះតទៅ រហូតដល់ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១០ ។

ហួសរយៈពេលកំណត់នេះ ក្រសួងព័ត៌មាន នឹងរៀបចំវិធានការតាមផ្លូវច្បាប់។

ព័ត៌មានបន្ថែមសូមធ្វើការទំនាក់ទំនងមក អគ្គនាយកដ្ឋានព័ត៌មាន និងសោតទស្សន៍ នៃក្រសួងព័ត៌មាន ។

ជ.រដ្ឋមន្ត្រី
រដ្ឋលេខាធិការ
ប្រធានគណៈអាជ្ញាធរគ្រប់គ្រងការផ្សព្វផ្សាយអាហ្វីស ប៉ាណូ

ព្រះរាជាណាចក្រកម្ពុជា
ក្រសួងព័ត៌មាន

អ៊ុក-ប្រាថ្នា

លេខទូរស័ព្ទទំនាក់ទំនង:
-០២៣ ៤៣០ ៣៣៦
-០៨៨ ២២៤ ២២២២
-០១២ ១០០ ៩៥០
-០១៦ ២២ ៨៨៨៩